# ឯកសារទស្សនទាន
# ឯកឧត្តម ខេង ស៊ុម ប្រធានក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ
# ក្នុងសន្និសីទសារព័ត៌មាន ស្តីពីវឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង
# ទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២២

- សូមក្រាបថ្វាយបង្គំ **សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ** ជាទីគោរពសក្ការៈ !
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព **ឯកឧត្តម កិត្តិកោសល្យបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាននាពេលនេះ ជាទីមេត្រី!
- បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ ជាទីគោរពស្រលាញ់រាប់អាន!

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**តាមរយៈការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម និងសុខភាពសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយមិនប្រកាន់និន្នាការនយោបាយព្រមទាំងយកចិត្តទុកដាក់ខ្ពស់លើជីវភាពរស់នៅ តាមរយៈការពង្រឹងសន្តិសុខស្បៀង អាហារូបត្ថម្ភ ជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គមឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីជានាលើកកម្ពស់សុខមាលភាពរបស់ប្រជាជន ដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានជាអតិបរមា និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖

-សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា

-ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្រ្តី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ និងលោកជំទាវ

-ឯកឧត្តម ទេសរដ្ឋមន្រ្តី **គន់ គីម** អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង

-ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំរាជរដ្ឋាភិបាលដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ទំនុកបំរុងជួយដល់ប្រជាពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យយើងខ្ញុំរាល់គ្រប់កាលៈទេសៈលំបាកទាំងអស់ដែលកើតមានឡើងក្នុងភូមិសាស្ត្រខេត្ត។

ថ្ងៃនេះ តាងនាមក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ និងក្នុងនាមខ្ញុំព្រះករុណា ខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីសោមនស្សរីករាយ ដោយត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល អនុញ្ញាតឲ្យចូលរួមជាវាគ្មិនកិត្តិយស ដើម្បីធ្វើបទបង្ហាញស្តីពី « **វឌ្ឍនភាពមូលដ្ឋានឃុំ/សង្កាត់ និងទិសដៅការងាររបស់ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ** » នាពេលនេះ ។

ខ្ញុំបាទ សូមគោរពរាយការណ៍ជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី អំពីស្ថានភាពភូមិសាស្រ្ត ប្រជាសាស្រ្ត សក្តានុពល សមិទ្ធផលនៃការអភិវឌ្ឍ ស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រងដឹកនាំ និងវឌ្ឍនភាពការងាររបស់ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ ដែលសម្រេចបានក្នុងរយៈពេល១ឆ្នាំកន្លងមក និងទិសដៅការងារដែលត្រូវយកចិត្តទុកដាក់អនុវត្តឆ្នាំ២០២២ ដូចតទៅ ៖

## I.**ស្ថានភាពភូមិសាស្ត្រ** ៖

ខេត្តបន្ទាយមានជ័យ ជាខេត្តមួយក្នុងចំណោមរាជធានី-ខេត្តទាំង២៥ទូទាំងប្រទេស ដែលមានចម្ងាយ ៣៦០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងកើតទល់នឹងខេត្តសៀមរាប ខាងលិចទល់នឹងព្រះរាជាណាចក្រថៃ ប្រវែង១៥៣គីឡូម៉ែត្រជាប់នឹងខេត្តស្រះកែវ និងខេត្តបូរីរ៉ុំ ខាងជើងទល់នឹងខេត្តឧត្តរមានជ័យ ខាងត្បូងទល់នឹងខេត្តបាត់ដំបង ។

ខេត្តមានផ្ទៃដីសរុប ៦.៦៧៩គីឡូម៉ែត្រការ៉េ បែកចេញជាក្រុង២ ស្រុក៧ ឃុំ៥៥ សង្កាត់១២ ភូមិទទួលស្គាល់៦៥៩ភូមិ មានចំនួនគ្រួសារ១៩៦.៤០០គ្រួសារ ចំនួនមនុស្ស៧៩៤.២៤៥នាក់ ក្នុងនោះស្រី ៤០៤.៥៩៥នាក់ មុខរបរសំខាន់របស់ប្រជាពលរដ្ឋ៨៥%ជាកសិករ ១០%ជាអាជីវករ ពាណិជ្ជករ និង៥% ប្រកបមុខរបរផ្សេងៗ ។

ខេត្តបន្ទាយមានជ័យ ចាប់បដិសន្ធិនាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៨៨ ដោយកាត់ចេញពីខេត្តបាត់ដំបង ដែលមុនការបង្កើតខេត្ត ទីរួមខេត្តនេះ ជាអតីតស្រុកសិរីសោភ័ណ ដែលគេនិយមថាស្រុកស្វាយស៊ីសូផុន កាលនោះ មានប្រជាពលរដ្ឋមិនជាច្រើននោះទេ ហេដ្ឋារចនាសម្ព័ន្ធនានានៅជួបការលំបាកនៅឡើយដោយសារជួបនឹងសង្រ្គាមរ៉ាំរ៉ៃ ខ្ទេចខ្ទាំ។ បន្ទាប់ពីទទួលបានសុខសន្តិភាពនាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ក្រោមនយោបាយ " **ឈ្នះ ឈ្នះ** " របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ខេត្តបន្ទាយមានជ័យ បានបោះជំហានទៅមុខយ៉ាងលឿន ក្រោមទង់សាមគ្គីជាតិ ឯកភាពជាតិ។

បើយើងធ្វើដំណើរពីរាជធានីភ្នំពេញ ឆ្លងកាត់ទីរួមខេត្តកំពង់ឆ្នាំង ទីរួមខេត្តពោធិ៍សាត់ និងទីរួមខេត្តបាត់ដំបង ចូលដល់ទឹកដីស្រុកមង្គលបូរី នៃខេត្តបន្ទាយមានជ័យ នោះនឹងឃើញភ្នំតូច ភ្នំធំ ភ្នំបន្ទាយនាង តំរៀបជាជួរតាមដងផ្លូវជាតិលេខ៥ និងមានភ្នំស្វាយស្ទាក់ពីមុខ ព្រមទាំងអគាររដ្ឋបាលខេត្តសង់នៅលើទីទួល ជាប់ជើងភ្នំដែលជាចំណុចប្រសព្វផ្លូវជាតិលេខ៥ ផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៥៦។ ចូលដល់ទីរួមខេត្ត មានរូបចំណាកស្រីគ្រប់លក្ខណ៍

ទាក់ទាញអ្នកដំណើរក្នុងទឹកមុខញញឹមប្រឹមប្រិយ រាក់ទាក់ រួសរាយ ក្នុងសម្លៀកបំពាក់ជានារីខ្មែរ ឈរលើអសនៈ កណ្ដាលរង្វង់មូល ដែលក្នុងចិត្តពោរពេញទៅដោយក្ដីសង្ឃឹមនៃភាពរីកចម្រើនរបស់មាតុភូមិអង្គរ ក៏ដូចប្រពៃណីទំនៀមទម្លាប់ ដែលដូនតារក្សាទុកពីអតីតកាល។ មកមុខបន្តិចទៀត រូបសំណាកព្រះអវលោកេតេស្វរៈ ដៃ៣២ តំណាងឲ្យប្រាសាទបន្ទាយឆ្មារ ដែលជាបេតិកភ័ណ្ឌវប្បធម៌ខ្មែរដ៏រុងរឿង បានប្រាប់ថា មកដល់ខេត្តបន្ទាយមានជ័យ កុំភ្លេចឈាងទៅមើល ទៅទស្សនា ឬទៅសិក្សារមណីយដ្ឋានប្រវត្តិសាស្ត្រនៅស្រុកថ្មពួក មានប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព បារាយណ៍មេបុណ្យ ព្រមទាំងប្រាសាទឧបសម្ព័ន្ធជាច្រើនទៀត ហើយក៏កុំភ្លេចរួបរួមគ្នាថែរក្សាការពារឲ្យបានគង់វង្សតរៀងទៅ។

ជាក់ស្ដែងក្នុងប្រភពទិន្នន័យឆ្នាំ២០១៧-២០២១ បានបង្ហាញថាផលិតផលក្នុងស្រុកសរុបនៃសេដ្ឋកិច្ចខេត្តទាំងមូលមានតម្លៃប្រមាណ ៣.៩០១.៣៥៨,៥លានរៀល (៣ទ្រីលាន ៩០១ប៊ីលាន ៣៥៨លាន ៥រយពាន់រៀលគត់) ឬស្មើនឹង៩៦៧លានដុល្លារសហរដ្ឋអាមេរិក។ បើតាមថ្លៃបច្ចុប្បន្នក្នុងឆ្នាំ២០១៨ ស្មើនឹង៤,២%នៃសេដ្ឋកិច្ចជាតិ។ បើធៀបនឹងឆ្នាំ២០១៧ សេដ្ឋកិច្ចខេត្តមាន៣.៩០១.៣៥៨,៥លានរៀល(៣ទ្រីលាន ៩០១ប៊ីលាន ៣៥៨លាន ៥រយពាន់រៀលគត់) ស្មើនឹង៩៦៧លានដុល្លារសហរដ្ឋអាមេរិក។ សេដ្ឋកិច្ចខេត្តឆ្នាំ២០១៨ មានកំណើន៦,៥% បើធៀបនឹងឆ្នាំ២០១៧ ដោយឡែកចំណូលសម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០១៧ មាន ១.២៤៥ ដុល្លារ និងចំណូលសម្រាប់ មនុស្សម្នាក់ៗក្នុងឆ្នាំ២០១៨ មាន១.៣៦៣ដុល្លារ កើនឡើងចំនួន១១៨ដុល្លារ។ ដោយសារកំណើនសេដ្ឋកិច្ចមានការកើនឡើង ទើបអត្រានៃភាពក្រីក្រទូទាំងខេត្តត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ពី១៧,៥% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម១២,៨% ក្នុងឆ្នាំ២០១៧ និងមកនៅត្រឹម១៤,៦១%ក្នុងឆ្នាំ២០២០ (ដោយសារបរិបទនៃជំងឺកូវីដ-១៩ បានធ្វើឲ្យសេដ្ឋកិច្ចខេត្តធ្លាក់ចុះប្រមាណ១,៨១%)។

## II.**ការងារអភិវឌ្ឍន៍ ៖**

ការអនុវត្តនូវកម្មវិធីកំណែទម្រង់ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា។ ខ្ញុំសូមធ្វើការកត់សម្គាល់នូវសមិទ្ធផលសំខាន់ៗមួយចំនួនដែលរដ្ឋបាលខេត្តបានខិតខំពុះពារសម្រេចបានមានជាអាទិ៍ ៖

### **១-ការផ្ដល់សេវារដ្ឋបាល និងសេវាសាធារណៈតាមច្រកចេញចូលតែមួយ ៖**

រដ្ឋបាលខេត្តបានជំរុញការផ្ដល់សេវារដ្ឋបាល និងសេវាសាធារណៈនៅតាមច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត និងក្រុង ស្រុកទាំង៩ យន្តការច្រកចេញចូលតែមួយនៅឃុំ សង្កាត់ទាំង៦៥ ដើម្បីឲ្យការផ្ដល់សេវាបានទាន់ពេលវេលា និងតម្លាភាព គណនេយ្យភាពជូនប្រជាពលរដ្ឋ តាមគោលការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ទេរមុខងារមកឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ឆ្នាំ២០២១ សេវាដែលបានផ្ដល់ដោយច្រកចេញចូលតែមួយខេត្ត មានចំនួន១១.៧៨៣ សេវា ចំណូលបានចំនួន៣.៤៣៤.៩៧៨.៧៨៥រៀល (៣ប៊ីលាន ៤៣៤លាន ៩៧៨ពាន់ ៧៨៥រៀល)។

### **២-ការអនុវត្តគម្រោងវិនិយោគខេត្ត**

គម្រោងវិនិយោគអភិវឌ្ឍន៍ខេត្តឆ្នាំ២០២១ សរុបចំនួន ១០គម្រោង កំពុងដំណើរការអនុវត្ត ០១គម្រោង និងបញ្ចប់ដំណើរការអនុវត្តចំនួន ០៩គម្រោង ។

### **៣-វិស័យកសិកម្ម ៖**

ការងារបង្កបង្កើនផលឆ្នាំ២០២១ ស្រូវវស្សាអនុវត្តបានលើផ្ទៃដីសរុប ២៦៤.៩០៥ ហ.ត លើផែនការ ២៥២.៣២០ ហ.ត ស្មើនឹង ១០៤.៩៩ %នៃផែនការ ២៥២.៣២០ ហ.ត ផ្ទៃដីប្រមូលផល ២៣៥.៦៥២ ហ.ត បរិមាណផលសរុប ៧៩៧.២៥៧ តោន ដំណាំឧស្សាហកម្ម និងដំណាំបន្លែ ១៣៦.៣៩៨ ហ.ត ក្នុងនោះដំឡូងមី ១០៥.០៦៦ ហ.ត ផ្ទៃដីប្រមូលផល ១០២.២៤២ ហ.ត បរិមាណផលសរុប ១.៩៦៤.០៩៩ តោន (ទិន្និផលជាមធ្យម ចន្លោះពី ២២ តោន ទៅ ២៥ តោន ក្នុងមួយ ហ.ត) ពោតក្រហម ១២.២៤៨ ហ.ត ផ្ទៃដីប្រមូលផល ១២.២៤៨ ហ.ត បរិមាណផលសរុប ១០៥.៣៤៨ តោន (ទិន្និផលជាមធ្យមចន្លោះពី ២២ តោន ទៅ ២៥ តោន ក្នុងមួយ ហ.ត)ដំណាំរួមផ្សំនិងបន្លែ ៤.៤៦២ ហ.ត ។ ស្រូវប្រាំងលើផែនការ ២២.០០០ ហ.ត អនុវត្តបាន ៥០.៥១១ ហ.ត ២២៩,៦០% ផ្ទៃដីប្រមូលផល ៤៧.៥១១ ហ.ត បរិមាណផលសរុប ២១០.៤២៨ តោន ។សរុបបរិមាណផលស្រូវទាំងប្រាំង និង វស្សា ចំនួន ១.០០៦.៦៨៥ តោន ។

| | | |
|---|---|---|
| តុល្យភាពស្បៀង៖ | ទុនពូជ ការបាត់បង់ពេលប្រមូលផល និងផ្សេងៗ | ១៣០.៨៦៩ តោន |
| | ត្រូវការស្បៀងក្នុង១ឆ្នាំ | ១៣១.៥៦៤ តោន |
| | បរិមាណស្រូវលើសពីតម្រូវការ | ៨៧៥.៨១៦ តោន |

**៤-វិស័យធនធានទឹក ៖**

ជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញឲ្យវិស័យកសិម្មមានការរីកចម្រើន ឆ្នាំកន្លងទៅនេះបានខិតខំស្តារ និង កែលំអប្រព័ន្ធអាងទឹកជាច្រើនកន្លែង ក្នុងការរក្សាទឹកទុកសម្រាប់ការស្រោចស្រពដំណាំស្រូវ និងដំណាំផ្សេងៗ។

សមិទ្ធផលនៃប្រព័ន្ធធារាសាស្ត្រដែលផ្តល់លទ្ធភាពក្នុងការស្រោចស្រព ទាំងតូចទាំងធំចំនួន៨៧ក្នុងនោះ បែងចែកជា ខ្នាតធំ០៦ប្រព័ន្ធ ខ្នាតមធ្យម៧៥ប្រព័ន្ធ និងខ្នាតតូច០៦ប្រព័ន្ធ ដែលខ្នាតធំស្រោចស្រពចាប់ពី ៥.០០០ហ.តឡើង ខ្នាតមធ្យមស្រោចស្រពក្រោម៥.០០០ហ.ត និងខ្នាតតូចស្រោចស្រពចាប់ពី៥០០ហ.តចុះ។

**៥-វិស័យសាធារណការ ៖**

ផ្លូវថ្នល់ជាផ្នែកមួយដ៏សំខាន់នៃការដឹកជញ្ជូនសេដ្ឋកិច្ច ខេត្តបន្ទាយមានជ័យមានផ្លូវថ្នល់ដែលចែកចេញជា ផ្លូវជាតិមានចំនួន៦ខ្សែ ប្រវែង៣៥០,៩៨គ.ម ផ្លូវខេត្តមានចំនួន១៥ខ្សែ ប្រវែងសរុប៣៥១,៥៣គ.ម ស្ពានឆ្លង កាត់ស្ទឹងចំនួន១១៨កន្លែង និងផ្លូវរថភ្លើងពីប៉ោយប៉ែត ទល់នឹងព្រំប្រទល់ខេត្តបាត់ដំបងប្រវែង៧៥គ.ម។

គម្រោងស្ថាបនាប្រព័ន្ធបណ្តាញលូ ប្រវែងសរុប១១០គ.ម និងស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់០១កន្លែង ព្រមទាំងស្ថានីយ៍បូមទឹក០៤កន្លែងក្នុងក្រុងសិរីសោភ័ណ ក្រោមហិរញ្ញប្បទានសម្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខ។

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ច្រកទ្វារអន្តរជាតិស្ទឹងបត់ ក្រោមការសម្របសម្រួលពីក្រសួងសាធារណការ និងដឹកជញ្ជូន អនុវត្តបានចំនួន៣៥% និងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៣។

**៦-វិស័យអភិវឌ្ឍន៍ជនបទ ៖**

- ផ្លូវថែទាំខួប ៣ខ្សែ ប្រវែង ៣២,៦០០ម៉ែត្រ
- ផ្លូវថែទាំប្រចាំចំនួន ៨ខ្សែ ប្រវែង ៩៩,០០០ម៉ែត្រ
- ដាំដើមឈើតាមផ្លូវជនបទបានចំនួន ១,០០០ដើម
- អន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវលិចទឹកឆ្នាំ២០២១ បាន១៤ខ្សែប្រវែង១២៧,៦៧០ម៉ែត្រ និងសាងសង់ លូរំដោះទឹកបាន១៦កន្លែង
- ស្ថាបនាផ្លូវក្រាលក្រួសក្រហមគម្រោងសាច់ប្រាក់ពលកម្ម ប្រវែង២៣៩,២៣០ម៉ែត្រ
- ស្ថាបនាផ្លូវក្រាលដីស គម្រោងសាច់ប្រាក់ពលកម្ម ប្រវែង១០០,១២៦ម៉ែត្រ

- ផ្តល់ពាងត្រងទឹកភ្លៀងចំណុះ១,០០០លីត្រ ដល់ប្រជាពលរដ្ឋចំនួន ៦២៤៣ាង ស្មើនឹង២០៨ខ្នងផ្ទះ នៅឃុំរហាត់ទឹក ស្រុកមង្គលបូរី
- សាងសង់អណ្តូងខួងបំពាក់ស្នប់បានចំនួន៤៨អណ្តូង នៅឃុំរហាត់ទឹក ស្រុកមង្គលបូរី
- សាងសង់ប្រព័ន្ធចែកចាយទឹកតាមទុយោសម្រាប់សហគមន៍បានចំនួន៤កន្លែង
- សាងសង់បង្គន់សាធារណៈតាមសាលារៀន របស់គម្រោងសាច់ប្រាក់ពលកម្ម ចំនួន១០ខ្នង មួយខ្នង ៨បន្ទប់
- សាងសង់បង្គន់ចល័តជូនមណ្ឌលសំចតតាមច្រកព្រំដែនសម្រាប់ពលករមកពីក្រៅប្រទេសបានចំនួន៣ ទីតាំង ស្មើនឹង១២បន្ទប់
- ជម្រុញបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល បានចំនួន២ឃុំ ក្នុងឃុំស្រះរាំង ស្រុកមង្គលបូរី និងឃុំស្ពានស្រែង ស្រុកភ្នំស្រុក និង១៥ភូមិ ក្នុងស្រុកមង្គលបូរី ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក និងស្រុកស្វាយចេក។

**៧-វិស័យពាណិជ្ជកម្ម ៖**

ឆ្នាំ២០២១ ការនាំចេញស្រូវអង្ករយើងគ្មានទេ ប៉ុន្តែក្នុងគោលបំណងរក្សាបាននូវការធ្វើពាណិជ្ជកម្មដោយសមធម៌ និងអនុលោមភាពជាមួយនឹងវិធានប្រភពដើមទំនិញ យើងបានផ្តល់ជូននូវការអនុញ្ញាតឲ្យនាំចូលអង្ករតាមព្រំដែនមានចំនួន០៩ច្បាប់ ស្មើនឹង ៦៣២,៥២តោន គិតជាទឹកប្រាក់ ២១០.៨៤០ដុល្លារសហរដ្ឋអាមេរិក។ ក្រៅពីស្រូវអង្ករ យើងបាននាំចេញកសិផលផ្សេងៗតាមរយៈការផ្តល់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញសម្រាប់នាំចេញមានចំនួន១.៥០៦ច្បាប់ ស្មើនឹង៣៧០.៧៤៨តោន គិតជាទឹកប្រាក់៣៥.៧៥៦.៦៥០ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ ដំឡូងមីមានចំនួន១.៤៥៤ច្បាប់ ស្មើនឹង៣៦៣.៥០០តោន គិតជាទឹកប្រាក់៣១.០៧៥.៨៥០ដុល្លារសហរដ្ឋអាមេរិក ស្វាយចន្ទីមានចំនួន២២ច្បាប់ ស្មើនឹង៥.៥០៨តោន គិតជាទឹកប្រាក់៤.៥០៦.៨០០ដុល្លារសហរដ្ឋអាមេរិក ម្ទេសមានចំនួន៣០ច្បាប់ ស្មើនឹង១.៧៤០តោន គិតជាទឹកប្រាក់១៧៤.០០០ដុល្លារសហរដ្ឋអាមេរិក និងផលិតផលកសិកម្មមួយចំនួនទៀតដែលកសិករផលិតបាន។

**៨-វិស័យសុខាភិបាល ៖**

មានមន្ទីរពេទ្យខេត្ត១កន្លែង មន្ទីរពេទ្យបង្អែក៨កន្លែង មណ្ឌលសុខភាព៦៨កន្លែង ប៉ុស្តិ៍សុខភាព១៣កន្លែង និងសេវាឯកជន រួមមាន បន្ទប់ពិគ្រោះព្យាបាលជំងឺ១៣៩កន្លែង បន្ទប់ព្យាបាលមាត់ធ្មេញ២៥កន្លែង បន្ទប់ថែទាំជំងឺ១៩៥កន្លែង បន្ទប់ពិនិត្យផ្ទៃពោះ១៣២កន្លែង បន្ទប់ពិសោធន៍០៩កន្លែង មន្ទីរសម្រាកព្យាបាល ២៨កន្លែង ពហុព្យាបាលជំងឺ០១កន្លែង បន្ទប់ព្យាបាលចក្ខុរោគ០១កន្លែង និងឱសថ-ឱសថស្ថានរង មានចំនួន ១៣៨កន្លែង។

**៩-វិស័យឧស្សាហកម្ម ៖**

-ក្នុងឆ្នាំ២០២១ ខេត្តមានតំបន់សេដ្ឋកិច្ចពិសេសចំនួន៤ ៖

- តំបន់សេដ្ឋកិច្ចពិសេសអូរនាង មានរោងច្រកចំនួន៤កន្លែង
- តំបន់សេដ្ឋកិច្ចពិសេសសានកូ មានរោងច្រកចំនួន១០កន្លែង
- តំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែតភីភីមានរោងច្រកចំនួន១កន្លែង
- សួនឧស្សាហកម្មក្រុងសិរីសោភ័ណ មានរោងច្រកចំនួន៣កន្លែង និង

មានរោងចក្រផ្សេងទៀត ស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្ម មានរោងចក្រចំនួន៣កន្លែង សរុបរោងចក្រទាំងអស់មានចំនួន២១រោងចក្រ។

-សហគ្រាសធនតូច និងមធ្យម និងសិប្បកម្មមានចំនួន១.១៩៦កន្លែង ។

-ការធ្វើវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករឯកជនដែលមានអាជ្ញាបណ្ណនៅក្នុងខេត្តបន្ទាយមានជ័យ មានចំនួន១២ក្រុមហ៊ុន និងប្រតិបត្តិករ៤កំពុងសិក្សាសមិទ្ធិលទ្ធភាព មាននៅ៤ស្រុក។ សរុបបរិមាណផលិតទឹកទូទាំងខេត្តរយៈពេលប្រាំឆ្នាំផលិតទឹកបានចំនួន ១១,៦៨៧,៨៧២ម$^{៣}$ កើនឡើង ១៨.២% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

-កម្លាំងពលកម្មសរុបចំនួន ១៣.៩៧១នាក់ ស្រី ៧.៤០០នាក់។

**៩-វិស័យទេសចរណ៍ ៖**

វិស័យទេសចរណ៍កម្ពុជាដែលជា "ទេសចរណ៍វប្បធម៌ និងធម្មជាតិ" ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកជាវិស័យអាទិភាពមួយដើរតួជា "មាសបៃតង" រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការការពារបរិស្ថានពោលគឺចូលរួមដល់ការកសាងសេដ្ឋកិច្ចបៃតងនៅកម្ពុជាដែលជាផ្នែកគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

ខេត្តបន្ទាយមានជ័យ មានសក្តានុពល ៖ ផ្នែកឧស្សាហកម្មទេសចរណ៍ សរុបមានចំនួន៣១៥កន្លែង ក្នុងនោះសណ្ឋាគារ មានចំនួន២៦កន្លែង ផ្ទះសំណាក់មានចំនួន៨៧កន្លែង ផ្ទះស្នាក់(Hom Stay) មានចំនួន០៦កន្លែង ភោជនីយដ្ឋាន មានចំនួន២៨កន្លែង អាហារដ្ឋានមានចំនួន៨៥កន្លែង ខារ៉ាអូខេ មានចំនួន២២កន្លែង ក្លឹបកម្សាន្ត មានចំនួន ០៣កន្លែង ម៉ាស្សានិងស្ប៉ា មានចំនួន៤១កន្លែង រមណីយដ្ឋានទេសចរណ៍ មានចំនួន០៩កន្លែង សហគមន៍ទេសចរណ៍ មានចំនួន០១កន្លែង សមាគមដឹកជញ្ជូនទេសចរណ៍ មានចំនួន០៤សមាគម សមាគមរថយន្តតាក់ស៊ី មានចំនួន០១សមាគម និងចំណតរថយន្តទេសចរណ៍ផ្លូវខ្លី មានចំនួន០២ចំណត ។ រដ្ឋបាលខេត្តបានធ្វើការប្រឡងប្រណាំងទីក្រុងស្អាត បរិស្ថានស្អាត បដិសណ្ឋារកិច្ចល្អ និងធ្វើការកែលំអផ្នែកសេវាកម្មម្ហូបអាហារ និងសេវាស្នាក់នៅ ព្រមទាំងកែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ពបារាយណ៍មេបុណ្យ និងក្រុងប៉ោយប៉ែត ក្រុងសិរីសោភ័ណ(ទីរួមខេត្តបន្ទាយមានជ័យ) ឱ្យមានសោភ័ណភាពដើម្បីទាក់ទាញភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់ និងមកទស្សនាកម្សាន្តក្នុងខេត្ត ។ ខេត្តបន្ទាយមានជ័យ មានក្រុងចំនួន២ គឺ ក្រុងសិរីសោភ័ណ និងក្រុងប៉ោយប៉ែត ដែលជាក្រុងបេក្ខភាព ក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតទទួលចំណាត់ ថ្នាក់ទីក្រុងស្អាតផ្ការំដួល២ទង និងក្រុងប៉ោយប៉ែត ទទួលចំណាត់ថ្នាក់ទីក្រុងស្អាតផ្ការំដួល២ទងដូចគ្នាផងដែរ។

**១០-វិស័យការងារ ៖**

រោងចក្រ/សហគ្រាស មានចំនួន២៩០កន្លែង បែងចែកជា១៧ ប្រភេទមុខរបរ ដែលមានកម្មករនិយោជិតសរុបចំនួន២៥.៥៣២នាក់ ស្រី១៤.៤៨៧នាក់ ក្នុងនោះ ជនបរទេសសរុបមានចំនួន១.៩១៥នាក់ ស្រី៧២៤នាក់។

សហជីពដែលបានចុះបញ្ជីការមានចំនួន០៥សហជីពមូលដ្ឋាន ស្ថិតក្នុងក្រុមហ៊ុនសេវាកម្ម កាស៊ីណូ មានចំនួន០៤សហជីព និងរោចក្រកាត់ដេរសម្លៀកបំពាក់មាន០១សហជីព។

ផ្តល់សៀវភៅការងារជនកម្ពុជា បានចំនួន១៩៩នាក់ ស្រី៥៥នាក់។

សហគ្រាសដែលមានជនបរទេស បានធ្វើអធិការកិច្ច បានចំនួន១២៣សហគ្រាស។ ចំនួនជនបរទេសដែលបានពិនិត្យឃើញ សរុបចំនួន១.៥៩០នាក់ ស្រី៤៧១នាក់ ផ្តល់ប័ណ្ណនិងសៀវភៅការងារថ្មី និងទិដ្ឋការចូលជនបរទេស បានចំនួន៦១២នាក់ ស្រី១៥៣នាក់។

ពន្យាសុពលភាពលើប័ណ្ណ និងសៀវភៅការងារជនបរទេស បានចំនួន១.៧២៣នាក់ ស្រី៥២៩នាក់។

ក្រុមហ៊ុនបានស្នើសុំប្រើប្រាស់ហត្ថពលកម្មជនបរទេស បានចំនួន៤២ក្រុមហ៊ុន។

III. **ទិសដៅបន្តរបស់រដ្ឋបាលខេត្តឆ្នាំ២០២២ ៖**

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលមានទស្សនវិស័យឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ ក្រុមប្រឹក្សាខេត្ត សូមដាក់ចេញ នូវទិសដៅការងារចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ប្រតិបត្តិឱ្យបានម៉ឺងម៉ាត់តាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ពង្រឹងផ្លូងសាមគ្គីភាព និងអនុវត្តឱ្យបានល្អនូវរបៀបរបបធ្វើការងាររវាងក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត
- ខិតខំអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការផ្ទេរអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព ពិសេសពង្រឹងរដ្ឋបាលឯកភាពក្រុង ស្រុក សំដៅបង្វិតសេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ និងមានប្រសិទ្ធភាព
- គិតគូរធ្វើយ៉ាងណាឱ្យមានអគាររដ្ឋបាលក្រុង ស្រុក និងអគារប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់ ស្តង់ដារ
- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋានដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- បន្តគាំទ្រក្នុងការអនុវត្តមុខងារដែលក្រសួង ស្ថាប័នថ្នាក់ជាតិ បានប្រគល់ជូន
- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយសំដៅបង្វិតសេវាសាធារណៈឱ្យនៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកាឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍ
- បន្តគាំទ្រ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងការផ្តល់សេវានៅមូលដ្ឋាន
- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងជំរុញដល់គណៈអភិបាលខេត្តឱ្យអនុវត្តតួនាទីភារកិច្ចស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
- បន្តពង្រឹង និងគាំទ្រដល់យន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការិយាល័យប្រជាពលរដ្ឋខេត្ត
- បន្តពង្រឹងទំនាក់ទំនងរវាងក្រុមប្រឹក្សា គណៈអភិបាល និងមន្ទីរ អង្គភាពនានា ក្នុងការអនុវត្តតួនាទី និងភារកិច្ច
- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ពិសេសតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- ជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ក្នុងន័យជានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ
- រដ្ឋបាលខេត្ត នឹងជម្រុញសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ "**៣កុំ និង៣ការពារ**" ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ ខ្ញុំបាទសូមគោរពជូនពរ**សម្តេចតេជោនាយករដ្ឋមន្ត្រី សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តមកិត្តិកោសល្យបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល គណៈប្រតិភូខេត្តបន្ទាយមានជ័យ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានដែលមានវត្តមាននៅទីនេះ សូមជួបប្រទះនូវពុទ្ធពរទាំង **៤ ប្រការ** គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ!**